# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**
លេខ...០៦៥/....ន. គ. ស/ស.គ.ហ./២៤

*ថ្ងៃ ពុធ ១០ រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨*
*រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ធ្នូ គ.ស.២០២៤*

## សេចក្តីជូនដំណឹង
## ស្តីពី
## កាតព្វកិច្ចនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤ មកនិយ័តករគណនេយ្យនិងសវនកម្ម

**និយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស.) នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)** មានកិត្តិយស សូមជម្រាបជូនដល់ **ម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ** ជ្រាបថា÷ អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ (ហៅកាត់ថា អង្គភាព) ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៤ ស្របតាមស្តង់ដាគណនេយ្យជាធរមាន មក **ន.គ.ស.** តាមពេលវេលាដូចខាងក្រោម÷

១. <u>សហគ្រាស និងអង្គភាព ដែលមិនរងសវនកម្មឯករាជ្យ</u> ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** **មិនឱ្យហួសថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៥**។ សហគ្រាស និងអង្គភាពដែលត្រូវបានអនុញ្ញាតឱ្យបិទបញ្ជីគណនេយ្យខុសពីថ្ងៃទី៣១ ខែធ្នូ ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** មិនឱ្យហួសរយៈពេល **៣ខែ ២០ថ្ងៃ** គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

២. <u>សហគ្រាស និងអង្គភាព ដែលរងសវនកម្មឯករាជ្យ</u> ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុរងសវនកម្មរួចមក **ន.គ.ស.** **មិនឱ្យហួសថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៥**។ សហគ្រាស និងអង្គភាពដែលត្រូវបានអនុញ្ញាតឱ្យបិទបញ្ជីគណនេយ្យខុសពីថ្ងៃទី៣១ ខែធ្នូ ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** មិនឱ្យហួសរយៈពេល **៦ខែ ២០ថ្ងៃ** គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

*ជាមួយគ្នានេះ ដើម្បីជួយដល់សហគ្រាស និងអង្គភាព អនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្មបានត្រឹមត្រូវ ជៀសផុតពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម **ន.គ.ស.** សូមរំលឹកអំពីកិច្ចការស្នូលមួយចំនួនដែលសហគ្រាស និងអង្គភាព ត្រូវអនុវត្តមានដូចខាងក្រោម÷*

១. ត្រូវកាន់បញ្ជីគណនេយ្យ ឱ្យបានត្រឹមត្រូវ។

២. ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន ឱ្យបានរួចរាល់មិនឱ្យហួស **រយៈពេល ៣ខែ** គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។ ស្តង់ដាគណនេយ្យជាធរមាន សំដៅដល់ស្តង់ដាររបាយ-ការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (Cambodia International Financial Reporting Standards-CIFRS) ឬ ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម (Cambodia International Financial Reporting Standards for Small and Medium Sized Entities-CIFRS for SMEs) ឬ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាព



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីមែល : info@acar.gov.kh
ទូរស័ព្ទ ៩៥៥ - ២៣ ៨៨២ ១១១
Phone: 023 882 111

មិនស្វែងរកប្រាក់ចំណេញ (Cambodian Financial Reporting Standards for Not-For-Profit Entities-CFRS for NFPEs)។

៣. ត្រូវបញ្ចប់ការងារសវនកម្មឯករាជ្យ និងបោះផ្សាយមតិសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ មិនឱ្យហួស **រយៈពេល ៦ខែ** គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ ប្រសិនបើសហគ្រាស ឬ អង្គភាពនោះស្ថិតក្នុងលក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យដូចមានចែងក្នុងប្រកាសលេខ ៥៦៣ សហវ. ប្រក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ។

៤. សហគ្រាស ឬ អង្គភាព ដែលមិនទាន់មានលេខអត្តសញ្ញាណកម្មរបាយការណ៍ហិរញ្ញវត្ថុ (FIN) ត្រូវស្នើសុំលេខ FIN ពី **ន.គ.ស.** ដោយអនុវត្តតាមបែបបទ និងនីតិវិធីប្រើប្រាស់ប្រព័ន្ធអនឡាញ (E-Filing)។ សហគ្រាស ឬ អង្គភាព ត្រូវដាក់លិខិតស្នើសុំផ្លាស់ប្តូរលេខ FIN មក **ន.គ.ស.** ឱ្យបានមុន **៦០ថ្ងៃ** នៃកាលបរិច្ឆេទផុតកំណត់ដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុ ក្នុងករណីសហគ្រាស ឬ អង្គភាពបានប្រែប្រួលការចាត់ថ្នាក់ជាសហគ្រាស ឬ អង្គភាព **រងសវនកម្មឯករាជ្យ ឬ មិនរងសវនកម្មឯករាជ្យ**។ ការយឺតយ៉ាវក្នុងការស្នើសុំប្តូរលេខ FIN នឹងនាំដល់ការយឺតយ៉ាវនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** ដែលជាកម្មវត្ថុនៃការរងពិន័យអន្តរការណ៍។

៥. សហគ្រាស ឬអង្គភាព អាចប្រើប្រាស់ថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថល របស់ **ន.គ.ស.** ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** ឬអាចប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុតាមអនឡាញ (E-Filing) ។

៦. សហគ្រាស ឬ អង្គភាព ត្រូវបង់កម្រៃសេវាសាធារណៈសម្រាប់ការទទួលរក្សាទុករបាយការណ៍ហិរញ្ញវត្ថុស្របតាមប្រកាសលេខ ០០១ អ.ស.ហ.ប្រ.ក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម។

៧. សហគ្រាស ឬ អង្គភាព អាចចាត់តាំងអ្នកតំណាងដើម្បីបំពេញកាតព្វកិច្ចគណនេយ្យនិងសវនកម្ម ជាមួយមន្ត្រី **ន.គ.ស.** ដោយអ្នកតំណាងអាចជាបុគ្គលិករបស់សហគ្រាស ឬ អង្គភាពផ្ទាល់ ឬជាក្រុមហ៊ុនគណនេយ្យ ឬជាក្រុមហ៊ុនសវនកម្ម ដែលមានអាជ្ញាបណ្ណនៅមានសុពលភាពពី **ន.គ.ស.** ដូចមាននៅក្នុងបញ្ជីភ្ជាប់មកជាមួយនឹងសេចក្តីជូនដំណឹងនេះ។ ម្ចាស់សហគ្រាស និងប្រធានអង្គភាព ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះរាល់សកម្មភាពរបស់អ្នកតំណាងរបស់ខ្លួន។ ក្នុងករណីអ្នកតំណាងជាក្រុមហ៊ុនគណនេយ្យ ឬក្រុមហ៊ុនសវនកម្ម ត្រូវមានលិខិតផ្ទេរសិទ្ធិពីម្ចាស់សហគ្រាស ឬ ប្រធានអង្គភាព។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមន្ត្រីរបស់ ន.គ.ស. តាមរយៈប្រព័ន្ធទូរស័ព្ទដូចខាងក្រោម៖**

- សហគ្រាសរងសវនកម្មឯករាជ្យ៖ ០៩៦ ៩ ១៩៩ ៩៩៨ / ០៧៧ ៨០៥ ៥៥២ / ០១០ ៦៩៤ ៦២ / ០១៦ ៥៩៨ ៣៨៦ / ០១០ ៧៣៦ ៨៣៥
- សហគ្រាសមិនរងសវនកម្មឯករាជ្យ៖ ០៩៣ ៩១៩ ១៩២ / ០៩៩ ៤២៩ ៣៩៨ / ០៧០ ៥៤៥ ៦៨៨ / ០៧០ ២១២ ២៣៦ / ០៦៩ ៥១៩ ៣៧១
- អង្គភាព៖ ០៨១ ៦៤៤ ៦៦៣ / ០៩២ ៦៨៨ ២៩៧ / ០៨៥ ៩០៤ ៨៤៨ / ០៨៥ ៤៤៤ ៤៨៨។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់សហគ្រាស និងប្រធានអង្គភាព ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយការទទួលខុសត្រូវខ្ពស់ ចាប់ពីពេលនេះតទៅ។

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម
សូមចូលរួមក្នុង Telegram Channel របស់និយ័តករគណនេយ្យនិងសវនកម្ម

**អគ្គនាយក**

**ឃ្វី ថារិន**